**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៚៙៙៚

**ក្រុមហ៊ុន គ្រេន ធ្វីន អ៊ិនធើណេសិនណល**

**(ខេមបូឌា) ភីអិលស៊ី**

# សេចក្តីប្រកាសព័ត៌មាន

# ស្តីពីលទ្ធផលកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក លើកទី៧ របស់

# ក្រុមហ៊ុន គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី

នាថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ចាប់ពីម៉ោង ០៨:០០ ព្រឹក ដល់ ១១:០០ ថ្ងៃត្រង់ នៅទីស្នាក់ការក្រុមហ៊ុន ដែលមានទីតាំងនៅ ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា លោក **Chen Tsung-Chi** ជាអភិបាល និងជានាយកប្រតិបត្តិរបស់ក្រុមហ៊ុន **គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី** ("**ក្រុមហ៊ុន**") និងជាតំណាងរបស់លោក **យ៉ាង សាវស៊ីន** ប្រធានក្រុមប្រឹក្សាភិបាល ត្រូវបានប្រគល់សិទ្ធជាប្រធានមហាសន្និបាតភាគហ៊ុនិកលើកទី៧ ("**មហាសន្និបាតភាគហ៊ុនិក**") និងបានដឹកនាំមហាសន្និបាតភាគហ៊ុនិករបស់ក្រុមហ៊ុននេះ តាមរយៈកិច្ចប្រជុំពីចំងាយ តាមប្រព័ន្ធ Zoom។

## សមាសភាពចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិក

១. គណៈអធិបតី និងភ្ញៀវកិត្តិយស និងភ្នាក់ងារបញ្ជិកាមូលបត្ររបស់ក្រុមហ៊ុន

២. គណៈកម្មការរៀបចំដំណើរការមហាសន្និបាតភាគហ៊ុនិក លើកទី៧

៣. ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន អាណត្តិទី២

៤. ភាគហ៊ុនិករបស់ក្រុមហ៊ុនដែលមានរាយនាមក្នុងបញ្ជីរាយនាមភាគហ៊ុនិក ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១*។

* បញ្ជីរាយនាមភាគហ៊ុនិក ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ ភាគហ៊ុនិកសរុប មានចំនួន ៨៧១ នាក់ ។

- ចំនួនភាគហ៊ុនិកដែលបានចុះឈ្មោះចូលរួមប្រជុំមហាសន្និបាត ចំនួន ២៣ នាក់ (គិតជាភាគហ៊ុន មានចំនួន ២៨.៤៨៨.១០៨ ភាគហ៊ុន) ស្មើនឹង ៧១,២២ % នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប។
- ចំនួនភាគហ៊ុនិកដែលមានវត្តមាន នាថ្ងៃប្រជុំមហាសន្និបាត មានចំនួន ១៧ នាក់ (គិតជាភាគហ៊ុន មានចំនួន ២៨.៤៨៤.៧២០ ភាគហ៊ុន) ស្មើនឹង ៧១,២១% នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប។
- ចំនួនភាគហ៊ុនិកដែលបានចុះឈ្មោះ អវត្តមាន នាថ្ងៃប្រជុំមហាសន្និបាត ចំនួន ៦ នាក់ (គិតជាភាគហ៊ុន មានចំនួន ៣.៣៨៨ ភាគហ៊ុន) ស្មើនឹង ០,០១% នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប។
- ចំនួនភាគហ៊ុនិកសរុបដែលអវត្តមាន នាថ្ងៃមហាសន្និបាត ចំនួន ៨៥៤ នាក់ (គិតជាភាគហ៊ុន មានចំនួន ១១.៥១៥.២៨០ ភាគហ៊ុន ស្មើនឹង ២៨,៧៩ % នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប។

## របៀបវារៈកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក

| | |
|---|---|
| ម៉ោង ៨:០០ - ៩:០០ | ការចុះឈ្មោះ |
| ម៉ោង ៩:០០ - ៩:១៥ | ប្រកាសហេតុ |
| ម៉ោង ៩:១៥ - ១០:១៥ | បទបង្ហាញស្តីពីរបាយការណ៍លទ្ធផលអាជីវកម្មរបស់ក្រុមហ៊ុន |
| ម៉ោង ១០:១៥ - ១១:០០ | ការបោះឆ្នោតអនុម័តលើការបែងចែកភាគលាភ |
| ម៉ោង ១១:០០ | មតិបញ្ចប់ និងសេចក្តីថ្លែងអំណរគុណ |

ការបែងចែកភាគលាភជូនភាគហ៊ុនិករបស់ក្រុមហ៊ុន ត្រូវបានយល់ព្រម និងអនុម័តដោយភាគហ៊ុនិករបស់ក្រុមហ៊ុន ដូច ខាងក្រោម ៖

ភាគលាភជាសាច់ប្រាក់ចំនួន ៦០០.០០០.០០០រៀល ប្រមាណជា ១៥០.០០០ ដុល្លារអាមេរិក ស្មើនឹង ៥០,១០% នៃប្រាក់ចំណេញក្រោយបង់ពន្ធប្រចាំឆ្នាំ២០២០ នឹងត្រូវបែងចែកជូនភាគហ៊ុនិក នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១។

១- ប្រភេទភាគលាភដែលបែងចែក : ជាសាច់ប្រាក់

២- រយៈពេលភាគលាភ : ប្រចាំឆ្នាំ២០២០

៣- អនុបាតនៃការសងភាគលាភ : ៥០,១០% នៃប្រាក់ចំណេញក្រោយបង់ពន្ធ ប្រចាំឆ្នាំ២០២០

៤- ភាគលាភសរុបដែលបែងចែក : ៦០០.០០០.០០០ រៀល

៥- ភាគលាភក្នុងមួយឯកតាមូលបត្រមកម្មសិទ្ធ : ១៥ រៀល

៦- កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកត្រូវទទួលបានភាគលាភ: ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១

៧- ការបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ: ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១

ក្នុងមហាសន្និបាតភាគហ៊ុនិកនេះ អង្គប្រជុំបានធ្វើបទបង្ហាញពីខ្លឹមសារលម្អិតនៃរបាយការណ៍ប្រតិបត្តិការ រួមទាំងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន សម្រាប់ដំណាច់ការិយបរិច្ឆេទឆ្នាំ២០២០ និងត្រីមាសនានា ឆ្នាំ២០២១ នេះ និងកិច្ចពិភាក្សាលើបញ្ហាផ្សេងៗរបស់ក្រុមហ៊ុន។

មហាសន្និបាតភាគហ៊ុនិកនេះ បានបញ្ចប់ទៅនៅវេលាម៉ោង ១១:០០ នាទី ព្រឹក នាថ្ងៃខែឆ្នាំ ដដែល ក្រោមបរិយាកាសទទួលខុសត្រូវខ្ពស់ និងឯកភាពគ្នា។

ថ្ងៃចន្ទ ១៤ កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១

**ក្រុមហ៊ុន ហ្គ្រេន ធ្វីន អិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី**

GRAND TWINS INTERNATIONAL (CAMBODIA) PLC.
KINGDOM OF CAMBODIA